ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ខុទ្ទកាល័យរដ្ឋមន្ត្រី

ក្រុមអ្នកនាំពាក្យ

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## ការរៀបចំទិវាមនុស្សគ-ថ្លង់កម្ពុជាលើកទី១១ និងអន្តរជាតិ លើកទី៦៦ ឆ្នាំ២០២៣ ក្រោមប្រធានបទ

## *"បរិយាបន្នការងារសម្រាប់មនុស្ស គ -ថ្លង់ ដើម្បីការអភិវឌ្ឍ"*

នៅព្រឹកថ្ងៃអាទិត្យ ទី១៧ ខែកញ្ញា ឆ្នាំ២០២៣ **ឯកឧត្តម ជា សុមេធី** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាប្រធានក្រុមប្រឹក្សាសកម្មភាពជនពិការ និង **លោកជំទាវ ជា ផល្គុន** បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងទិវាមនុស្សគ-ថ្លង់កម្ពុជាលើកទី១១ និងអន្តរជាតិលើកទី៦៦ ឆ្នាំ២០២៣ ក្រោមប្រធានបទ "**បរិយាបន្នការងារសម្រាប់មនុស្ស គ -ថ្លង់ ដើម្បីការអភិវឌ្ឍ**"។ ទិវានេះមានការអញ្ជើញចូលរួមពីឥស្សរជនតំណាងក្រសួង ស្ថាប័ន អភិបាលរងនៃគណៈអភិបាលរាជធានី ខេត្ត អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ មនុស្សគ-ថ្លង់ និងជនមានពិការភាពសរុបចំនួនប្រមាណ ៤០០នាក់ នៅទីស្តីការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាអគ្គលេខាធិការក្រុមប្រឹក្សាសកម្មភាពជនពិការ **ឯកឧត្តម ឯម ច័ន្ទមករា** បានមានប្រសាសន៍ថា នៅលើពិភពលោក ទិវាមនុស្សគ-ថ្លង់ត្រូវបានប្រារព្ធឡើងជារៀងរាល់ឆ្នាំ ចាប់តាំងពីឆ្នាំ១៩៥៨ មកម្ល៉េះ។ រហូតមកដល់បច្ចុប្បន្ននេះមានប្រទេសប្រមាណ១៣៣ លើពិភពលោកបាននឹងកំពុងបន្តរៀបចំព្រឹត្តិការណ៍នេះ។ ការរៀបចំទិវានេះ មានលក្ខណៈផ្សេងៗតាមការនិយម តាមបែបប្រពៃណីនិងទំនៀមទម្លាប់ខុសៗគ្នាពីប្រទេសមួយទៅប្រទេសមួយ និងមានប្រធានបទផ្សេងៗគ្នាតាមឆ្នាំនីមួយៗ។ ប្រទេសខ្លះបានរៀបចំជាការដង្ហែក្បួន ជាកិច្ចប្រជុំពិភាក្សា ការប្រគំតន្ត្រី សិក្ខាសាលា សន្និបាតមិត្តិញជាដើម។

**ឯកឧត្តម ឯម ច័ន្ទមករា** បានបញ្ជាក់ថា នៅព្រះរាជាណាចក្រកម្ពុជា ការរៀបចំទិវាមនុស្សគ-ថ្លង់នេះ ត្រូវបានរៀបចំឡើងក្នុងកម្រិតថ្នាក់ជាតិចាប់តាំងពីឆ្នាំ២០១៣មកម្ល៉េះ ដែលជា

ការបង្ហាញឱ្យឃើញអំពីការគិតគូរយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល សាធារណៈជន សង្គមស៊ីវិល ក្រុមគ្រួសារ មិត្តភក្តិដើម្បីលើកទឹកចិត្ត ហើយបំពេញតាមតម្រូវការរបស់មនុស្សគ-ថ្លង់ ព្រមទាំងបង្កើនការលើកកម្ពស់សិទ្ធិ និងសេរីភាពរបស់មនុស្សគ-ថ្លង់នៅលើពិភពលោក។

ជាមួយគ្នានេះ អគ្គលេខាធិការក្រុមប្រឹក្សាសកម្មភាពជនពិការ **ឯកឧត្តម ឯម ច័ន្ទមករា** បានបន្តទៀតថា អង្គការសហប្រជាជាតិបានកំណត់យកថ្ងៃទី២៣ ខែកញ្ញា ជារៀងរាល់ឆ្នាំ ដើម្បីប្រារព្ធទិវាមនុស្សគថ្លង់អន្តរជាតិ ដែលជាការទទួលស្គាល់ពីសារៈសំខាន់នៃមនុស្សគ-ថ្លង់ ដែលជាសមាសភាពធនធានមនុស្ស និងមិនត្រូវបានមើលរំលងដើម្បីឈានទៅសម្រេចឱ្យខាងតែបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ពិសេសជាការបំពេញតាមការសន្យារបស់រដ្ឋជាភាគីនៃអនុសញ្ញាស្តីពីសិទ្ធិជនមានពិការភាព និងស្របតាមទិសស្លោក “**មិនទុកឱ្យនរណាម្នាក់នៅដាច់ដោយឡែក**”។

ថ្លែងក្នុងទិវានោះ **ឯកឧត្តម ជា សុមេធី រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាប្រធានក្រុមប្រឹក្សាសកម្មភាពជនពិការ** បាននាំមកនូវការផ្តាំផ្ញើ សាកសួរសុខទុក្ខពីសំណាក់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានកិត្តិយសក្រុមប្រឹក្សាសកម្មភាពជនពិការ និងលោកជំទាវ** ដែលតែងបានផ្តល់នូវក្តីអាណិតស្រលាញ់ សណ្តោសប្រណីយកចិត្តទុកដាក់ និងគិតគូរខ្ពស់ពីសុខទុក្ខរបស់បងប្អូនជនមានពិការភាពគ្រប់រូប។

**ឯកឧត្តម ជា សុមេធី** បានមានប្រសាសន៍បន្តថាការរៀបចំទិវានេះឡើង គឺជាការផ្តល់ឱកាសជួបជុំគ្នាក្នុងមួយឆ្នាំម្តងរវាងថ្នាក់ដឹកនាំក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិល និងបងប្អូនកូនក្មួយមនុស្សគ-ថ្លង់ ដែលជាការបង្ហាញអំពីការផ្តល់សិទ្ធិក្នុងការចូលរួមដោយឥតរើសអើង និងជាការលើកស្ទួយតម្លៃមនុស្សគ-ថ្លង់ ពិសេសធ្វើយ៉ាងណាឱ្យមានបរិយាបន្នការងារសម្រាប់មនុស្សគ-ថ្លង់ស្របតាមប្រធានបទក្នុងទិវានេះ ដែលជាការគិតគូរពីឧត្តមប្រយោជន៍របស់មនុស្ស គ-ថ្លង់នៅកម្ពុជា។

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា **ឯកឧត្តម ជា សុមេធី** បានសង្កត់ធ្ងន់ថា រាជរដ្ឋាភិបាលបានយល់ច្បាស់ពីតម្រូវការ បញ្ហាប្រឈមនានារបស់ជនមានពិការភាពជាពិសេសបងប្អូនកូនក្មួយ ក្រុមគ្រួសារមនុស្សគ-ថ្លង់។ ឈរលើបរិការណ៍ និងស្មារតីទទួលខុសត្រូវនេះ រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតឈ្លាសវៃបំផុតរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រ**កម្ពុជា** បានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដែលគ្របដណ្តប់ទៅលើកិច្ចការងារ

អាទិភាពជាច្រើន ក្នុងនោះវិស័យពិការភាពក៏ត្រូវបានចាត់ទុក ជាចក្ខុវិស័យរយៈពេលវែងសម្រាប់អភិវឌ្ឍដែលជាផ្នែកមួយនៃប្រព័ន្ធគាំពារសង្គម។

**ឯកឧត្តម ឌា សុមេធី** បានអំពាវនាវដល់គ្រប់ភាគីទាំងអស់បន្តយកចិត្តទុកដាក់ លើកស្ទួយសុខុមាលភាពជនមានពិការភាព ពិសេសមនុស្សគ-ថ្លង់នៅកម្ពុជា ដោយប្រែក្លាយផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព និងឯកសារគតិយុត្តិទាំងឡាយពាក់ព័ន្ធនឹងពិការភាពឱ្យក្លាយជាការពិត។

គួរបញ្ជាក់ផងដែរថា÷ ទិវានេះផ្តល់ឱកាសដើម្បីគាំទ្រនិងការពារអត្តសញ្ញាណភាសាសញ្ញា និងភាពចម្រុះនៃវប្បធម៌របស់អ្នកប្រើប្រាស់ភាសាសញ្ញាទាំងនៅព្រះរាជាណាចក្រកម្ពុជា និងនៅលើពិភពលោក។ ភាសាសញ្ញា គឺជាមធ្យោបាយដ៏សំខាន់សម្រាប់មនុស្សគ-ថ្លង់ ដើម្បីបង្ហាញពីខ្លួនឯង ភ្ជាប់ទំនាក់ទំនងជាមួយអ្នកដទៃ និងចូលរួមក្នុងគ្រប់វិស័យនៃសេដ្ឋកិច្ច សង្គម វប្បធម៌ និងនយោបាយ។ ការប្រើប្រាស់ភាសាសញ្ញា ក៏មានសារៈសំខាន់ផងដែរក្នុងការធានាការទទួលបានព័ត៌មាន និងការទទួលបាននូវសេវាកម្មនានា រាប់បញ្ចូលទាំងក្នុងគ្រាពេលមានអាសន្ន ដែលជាការបំពេញនូវសិទ្ធិសម្រាប់មនុស្សគ-ថ្លង់ជាង៧០លាននាក់នៅជុំវិញពិភពលោក។

ថ្ងៃអាទិត្យ ៣កើត ខែភទ្របទ ឆ្នាំថោះ ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៣